**NEWS RELEASE**

UNITED NATIONS
HUMAN RIGHTS
SPECIAL PROCEDURES
SPECIAL RAPPORTEURS, INDEPENDENT EXPERTS & WORKING GROUPS

# ប្រទេសកម្ពុជា៖ អ្នកជំនាញ អ.ស.ប មានក្តីបារម្ភចំពោះការកើនឡើងនៃភាពតានតឹង និងវិធានការបង្ក្រាប

ទីក្រុងហ្សឺណែវ (ថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០១៩) - អ្នករាយការណ៍ពិសេស អ.ស.ប ស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា បានបង្ហាញក្តីបារម្ភយ៉ាងខ្លាំងអំពីការបង្ក្រាបខាងនយោបាយដែលមានលក្ខណៈកាន់តែខ្លាំងឡើងៗនៅទូទាំងប្រទេស ហើយធ្វើការអំពាវនាវឲ្យរដ្ឋាភិបាលគោរពនូវសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ យោបល់ និងការជួបប្រជុំ។

ចាប់តាំងពីខែសីហា អ្នកស្រី រ៉ូណា ស្មីត បាននិយាយថា អ្នកស្រីបានទទួលព័ត៌មានគួរឲ្យជឿទុកចិត្តថា មានមនុស្សយ៉ាងតិចចំនួន ៨៩ នាក់ ត្រូវបានចោទប្រកាន់ពីបទ «រួមគំនិតក្បត់ ប្រឆាំងនឹងរដ្ឋ» ហើយយ៉ាងហោចណាស់ក៏មានមនុស្សចំនួន ៥២ នាក់ ត្រូវបានចាប់ខ្លួន នៅតាមបណ្តាខេត្តចំនួន ២០ ។ ព្រឹត្តិការណ៍នេះនាំឲ្យមានការកើនឡើងនូវករណីនៃការឃាយីធ្វើទុក្ខបុកម្នេញ និងចំណាត់ការតាមផ្លូវ-តុលាការប្រឆាំងនឹងសមាជិក ឬអ្នកគាំទ្រគណបក្សសង្គ្រោះជាតិ ចំនួនជាង ២០០ ករណី រាប់ចាប់តាំងពីថ្ងៃទី១ ខែមករា ឆ្នាំ២០១៩ ។

លោក សម រង្ស៊ី អតីតមេដឹកនាំគណបក្សប្រឆាំង ពោលគឺគណបក្សសង្គ្រោះជាតិកម្ពុជា ដែលត្រូវបានដាក់ឲ្យនៅក្រៅច្បាប់ បានថ្លែងថា លោកនឹងវិលត្រឡប់ពីការនិរទេសខ្លួន នៅថ្ងៃទី៩ ខែវិច្ឆិកា។ លោកនាយករដ្ឋមន្ត្រីប្រកាសថា លោក រង្ស៊ី នឹងត្រូវចាប់ខ្លួននៅពេលមកដល់ប្រទេសកម្ពុជា ដោយសារគាត់ត្រូវបានតុលាការកាត់ទោសកំបាំងមុខ និងផ្តន្ទាទោសដាក់ពន្ធនាគារ។

«ការកើនឡើងយ៉ាងឆាប់រហ័សនូវចំនួននៃការចាប់ខ្លួន និងការចោទប្រកាន់យ៉ាងធ្ងន់ធ្ងរទៅលើសមាជិកគណបក្សសង្គ្រោះជាតិ កំពុងស្ថិតនៅក្នុងស្ថានភាពអាសន្ន» នេះបើតាមប្រសាសន៍របស់អ្នកស្រី ស្មីត អ្នកជំនាញឯករាជ្យដែលត្រូវបានតែងតាំងដោយក្រុមប្រឹក្សាសិទ្ធិមនុស្ស។ «គេមិនត្រូវអនុញ្ញាតឲ្យមានការចាប់ខ្លួនទាំងឡាយ ដោយគ្រាន់តែផ្អែកលើមូលហេតុនៃការអនុវត្តសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិយោបល់ តាមរយៈការថ្លែងសារនយោបាយ និងការធ្វើអត្ថាធិប្បាយទៅលើកិច្ចការសាធារណៈឡើយ។ ប្រទេសកម្ពុជាត្រូវតែគោរពកាតព្វកិច្ចអន្តរជាតិរបស់ខ្លួន»។

អង្គការសង្គមស៊ីវិល ក៏បានរាយការណ៍ផងដែរ អំពីការកើនឡើងនៃការតាមដានឃ្លាំមើលពីសំណាក់អាជ្ញាធរមូលដ្ឋាន និងការរឹតត្បិតទៅលើសកម្មភាពរបស់ពួកគេ។ អ្នកស្រី ស្មីត បានមានប្រសាសន៍ថា «អង្គការសង្គមស៊ីវិល គួរតែអាចធ្វើការងារដោយសេរីនៅក្នុងប្រទេសកម្ពុជា» ។

ការកើនឡើងគួរឲ្យកត់សម្គាល់អំពីការដាក់ពង្រាយកងកម្លាំងប្រដាប់អាវុធ រួមទាំងនគរបាល និងកងរាជអាវុធហត្ថ ក៏ត្រូវបានរាយការណ៍ផងដែរ ហើយកងកម្លាំងទាំងនោះបានប្រមូលផ្តុំ នៅតាមច្រកព្រំដែន និងតាមភូមិនានា ដែលអមដោយយានយន្តយោធា និងមនុស្សដែលប្រដាប់ដោយអាវុធ។ អ្នកស្រី ស្មីត បានមានប្រសាសន៍ថា «ខ្ញុំជំរុញឲ្យមន្ត្រីអនុវត្តច្បាប់ ប្រើប្រាស់មធ្យោបាយអហិង្សា នៅមុនពេលមានការប្រើប្រាស់កម្លាំង និងអាវុធ ហើយខ្ញុំសូមអំពាវនាវឲ្យមនុស្សទាំងអស់ធ្វើសកម្មភាពដោយសន្តិវិធី និងមានភាពអត់ធ្មត់ទាំងពាក្យសម្តី និងសកម្មភាព»។

«ថ្ងៃសៅរ៍នេះ គឺជាទិវាបុណ្យឯករាជ្យជាតិរបស់ប្រទេសកម្ពុជា ដើម្បីរំឭកដល់ថ្ងៃដែលប្រទេសនេះបានរួចចាកផុតពីរបបអាណានិគមនិយម ហើយថ្ងៃនោះក៏ជាថ្ងៃត្រៀមចូលថ្ងៃបុណ្យអុំទូក ដែលជានិមិត្តរូបនៃការបិទបញ្ចប់រដូវវស្សា។ ថ្ងៃបុណ្យទាំងពីរប្រភេទនេះ ត្រូវបានប្រកាសប្រារព្ធជាថ្ងៃឈប់សម្រាកការងារប្រចាំឆ្នាំ ហើយមនុស្សជាច្រើនធ្វើដំណើរមកចូលរួមពិធីទាំងនេះ នៅរាជធានីភ្នំពេញ»។ អ្នកជំនាញឯករាជ្យ កត់សម្គាល់ថា ទន្ទឹមនឹងការរឹតបន្តឹងសន្តិសុខ ដែលអាចធ្វើឡើងនៅក្នុងអំឡុងពេលនេះក៏ដោយ «ក៏មនុស្សគ្រប់រូបមានសិទ្ធិចូលរួម និងអបអរការប្រារព្ធពិធីតាមបែបវប្បធម៌ប្រពៃណីទាំងនេះ ប្រកបដោយសុវត្ថិភាព សន្តិវិធី និងដោយមិនមានការភ័យខ្លាច»។

អ្នកស្រី ស្មីត បានសម្តែងកង្វល់ផងដែរ ចំពោះការឃុំខ្លួនសមាជិកគណបក្សសង្គ្រោះជាតិ នៅក្នុងបណ្តាប្រទេសជិតខាង នាពេលថ្មីៗនេះ បន្ទាប់ពីពួកគេប៉ុនប៉ងធ្វើដំណើរចូលមកប្រទេសកម្ពុជា។ អ្នកស្រីបានជំរុញឲ្យរដ្ឋនានា ធ្វើការលើកទឹកចិត្តឲ្យមានកិច្ចសន្ទនាប្រកបដោយសន្តិវិធី ដើម្បីដោះស្រាយការខ្វែងគំនិតគ្នា និងគោរពដល់សេរីភាពក្នុងការធ្វើដំណើរ។

អ្នកស្រីមានប្រសាសន៍ថា «ខ្ញុំសូមអំពាវនាវដល់រដ្ឋាភិបាល និងគ្រប់ភាគីទាំងអស់ ធ្វើការកាត់បន្ថយនូវស្ថានភាពដែលវិវឌ្ឍន៍ទៅរកភាពតានតឹង ហើយស្វែងរកការសន្ទនាគ្នានៅក្នុងបរិយាកាសប្រកបដោយសន្តិវិធី និងដែលអនុញ្ញាតឲ្យមានការបញ្ចេញនូវមតិនយោបាយផ្ទុយគ្នា ដោយចៀសវាងការរឹតត្បិតណាមួយបន្ថែមទៀតទៅលើសេរីភាពជាមូលដ្ឋាន ដែលជាគ្រឹះនៃការទទួលបានការអនុវត្តសិទ្ធិមនុស្សសម្រាប់ទាំងអស់គ្នា»។

**ចប់**

***សាស្ត្រាចារ្យ រ៉ូណា ស្មីត*** *(ចក្រភពអង់គ្លេស) ត្រូវបានក្រុមប្រឹក្សាសិទ្ធិមនុស្ស អ.ស.ប តែងតាំងជា* *អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ក្នុងខែមីនា ឆ្នាំ២០១៥។*

*អ្នករាយការណ៍ពិសេស ពួកគាត់គឺជាផ្នែកមួយនៃអ្វីដែលគេស្គាល់ថាជានីតិវិធីពិសេសរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស។ នីតិវិធីពិសេស (ស្ថាប័នដ៏ធំបំផុតមួយនៃអ្នកជំនាញឯករាជ្យ ក្នុងប្រព័ន្ធសិទ្ធិមនុស្ស អ.ស.ប) គឺជាឈ្មោះទូទៅមួយនៃយន្តការឃ្លាំមើល និងស្វែងរកការពិតឯករាជ្យរបស់ក្រុមប្រឹក្សានេះ។ អ្នកកាន់អាណត្តិនីតិវិធីពិសេស គឺជាអ្នកជំនាញឯករាជ្យផ្នែកសិទ្ធិមនុស្ស ដែលក្រុមប្រឹក្សាសិទ្ធិមនុស្សបានតែងតាំងឡើង ដើម្បីធ្វើការងារពាក់ព័ន្ធនឹងស្ថានភាពសិទ្ធិមនុស្សរបស់ប្រទេសមួយជាក់លាក់ ឬពាក់ព័ន្ធនឹងបញ្ហាសិទ្ធិមនុស្សតាមវិស័យនីមួយៗនៅគ្រប់កន្លែងទាំងអស់លើពិភពលោក។ ពួកគាត់មិនមែនជាបុគ្គលិក អ.ស.ប ទេ ហើយធ្វើការងារដោយឯករាជ្យពីរដ្ឋាភិបាល និងអង្គការទាំងឡាយ។ ពួកគាត់បម្រើការងារក្នុងសមត្ថភាពបុគ្គលផ្ទាល់របស់ខ្លួន ហើយមិនទទួលប្រាក់បៀវត្សរ៍លើការងារនេះឡើយ។*

*ពិនិត្យមើលរបាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីប្រទេសកម្ពុជា និងមើលទំព័រហ្វេសប៊ុករបស់អ្នករាយការណ៍ពិសេស*
*https://www.facebook.com/SpecialRapporteurCambodia/?modal=admin_todo_tour*

*សិទ្ធិមនុស្ស អ.ស.ប ទំព័រប្រទេស៖ ប្រទេសកម្ពុជា*

*សម្រាប់ព័ត៌មានបន្ថែម និងការសាកសួរព័ត៌មានផ្សេងៗ សូមទាក់ទង៖*
*អ្នកស្រី អ៊ីស្ទើរ ឡាំ (Esther Lam) តាមរយៈទូរស័ព្ទលេខ៖ (+៤១ ២២ ៩២៨ ៩១ ០៨ ឬ អ៊ីម៉ែល elam@ohchr.org) និង លោក ម៉ាសម៉ូដ ហ្គារហ្គា តាមរយៈទូរស័ព្ទ៖ (+៨៥៥ (0)១២ ៧៩០ ១៧៨ អ៊ីម៉ែល mgarga@ohchr.org)*

*សម្រាប់**ការសាកសួរព័ត៌មាន**ពាក់ព័ន្ធនឹងអ្នកជំនាញឯករាជ្យដទៃទៀតរបស់ អ.ស.ប សូមទាក់ទង៖*
*លោក ហេរ្សមី ឡូរង់ស៍ សិទ្ធិមនុស្ស អ.ស.ប – អង្គភាពប្រព័ន្ធផ្សព្វផ្សាយ តាមរយៈទូរស័ព្ទលេខ៖ (+៤១ ២២ ៩១៧ ៩៣៨៣ ឬ អ៊ីម៉ែល jlaurence@ohchr.org)*